# នីតិវិធីនៃការចាត់ចែងរក្សាការពារ

## ១. សេចក្តីផ្តើម

នៅក្នុងសង្គមមួយរមែងតែងតែមានទំនាក់ទំនងរវាងបុគ្គលដែលរស់នៅក្នុងសង្គមនោះ ទំនាក់ទំនងទាំងនោះហើយដែលបង្កើតអោយមានស្ថានភាពគតិយុត្តជាច្រើន។ ដោយសារមានស្ថានភាពអសកម្មមួយចំនួនរបស់បុគ្គលដែលជាភាគីនៃទំនាក់ទំនងគតិយុត្តទាំងនោះ ដែលបង្កើតអោយមានបុគ្គលដែលមានសិទ្ធិ និងបុគ្គលដែលត្រូវបំពេញកាតព្វកិច្ច ហើយនៅពេលដែលបុគ្គលដែលត្រូវបំពេញកាតព្វកិច្ចមិនព្រមបំពេញកាតព្វកិច្ចរបស់ខ្លួនដោយប្រការណាមួយនោះ វិវាទរវាងសិទ្ធិនិង កាតព្វកិច្ចនឹងកើតមានឡើង។ ដើម្បីដោះស្រាយអំពីវិវាទ ដែលកើតចេញពីសិទ្ធិនឹងកាតព្វកិច្ចដែលមានចែងក្នុងក្រមរដ្ឋប្បវេណីនេះ បុគ្គលដែលមានសិទ្ធិត្រូវធ្វើបណ្តឹងទៅតុលាការរដ្ឋប្បវេណី ដើម្បីអនុវត្តសិទ្ធិរបស់ខ្លួន ក៏ដូចជាការទាមទារអោយភាគីម្ខាងទៀតបំពេញកាតព្វកិច្ចចំពោះខ្លួនផងដែរ ។ នៅក្នុងរឿងក្តីរដ្ឋប្បវេណីអ្នកដែលមានសិទ្ធិហៅថា ***ម្ចាស់បំណុល*** ចំណែកឯអ្នកមានកាតព្វកិច្ចហៅថា ***កូនបំណុល*** ។ ទម្រាំមានការសម្រេចជាស្ថាពរនៅសិទ្ធិរបស់ម្ចាស់បំណុលត្រូវប្រើពេលវេលាយូរ ដែលនាំអោយសិទ្ធិដែលត្រូវអនុវត្តនាពេលអនាគតអាចនឹងត្រូវពិបាកក្នុងការអនុវត្ត ឬពេលខ្លះអាចនឹងអនុវត្តមិនបានថែមទៀតផង ព្រោះតែមានការប្រែប្រួលនៅស្ថានភាពទ្រព្យសម្បត្តិរបស់កូនបំណុលក្នុងអំឡុងពេលនៃនីតិវិធីបណ្តឹង ហេតុនេះដើម្បីសម្របសម្រួលស្ថានភាពបែបនេះ ក៏ដូចជាការពារនៅក្តីរំពឹងរបស់អ្នកឈ្នះក្តីថាក្រោយពីបានឈ្នះក្តីហើយ ពួកគេអាចអនុ-វត្តសិទ្ធិរបស់ពួកគេបានដោយរលូននោះ ទើបក្រមនីតិវិធីរដ្ឋប្បវេណីបង្កើតអោយមានយន្តការក្នុងការរក្សាការពារនៅទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីបង្ការ ទប់ស្កាត់ជាមុន កុំអោយមានការប្រែប្រួល ឬបាត់បង់ទាំងស្រុងនៅទ្រព្យសម្បត្តិរបស់កូនបំណុល ដែលជាហេតុធ្វើអោយម្ចាស់បំណុលមិនអាចអនុវត្តសិទ្ធិលើបំណុលរបស់ខ្លួនបាន ។ នៅមានបញ្ហាប្រឈមមួយទៀតដែលតម្រូវអោយមានប្រព័ន្ធនៃការរក្សាការនេះ គឺបញ្ហាឋានៈរបស់បុគ្គល មានស្ថានភាពមួយចំនួនបុគ្គលដែលរងគ្រោះ ឬបុគ្គលមួយចំនួនដែលត្រូវការប្រព័ន្ធរក្សាការពារនេះជាចាំបាច់ដើម្បីកំណត់ឋានៈរបស់ពួកគេជាមុន ដើម្បីការពារស្ថានការបន្ទាន់ដើម្បីទទួលបានការសង្គ្រោះអោយសមស្របនឹងពេលវេលា ព្រោះថាស្ថានភាពមួយចំនួនមិនអាចអោយពួកគេរង់ចាំរហូតដល់មានសាលក្រមឬសាលដីកាស្ថាពរជាមុនសិនទើបទទួលបានសិទ្ធិនោះទេ ។

តើអ្វីទៅជានីតិវិធីរក្សាការពារ ? ដើម្បីបង្កើតការរក្សាការពារម្ចាស់បំណុលត្រូវមានសិទ្ធិ និងភាពចាំបាច់ដូចម្តេចខ្លះ ?

## ២. សញ្ញាណទូទៅ

នីតិវិធីរក្សាការពារ គឺជានីតិវិធីដែលមានចរិកលក្ខណៈជាការបំពេញបន្ថែមទៅលើនៅនីតិវិធីអនុវត្តដោយបង្ខំ ព្រោះថាការរក្សាការពារក៏ជានីតិវិធីអនុវត្តដោយបង្ខំមួយដែរ ប៉ុន្តែវាមានលក្ខណៈប្លែកពីការ អនុវត្តដោយបង្ខំដោយសារនីតិវិធីនេះមានចែកចេញជាពីរតំណាក់ការគឺ ៖ នីតិវិធីនៃការសម្រេចសេក្តី ដែលជាការវិនិច្ឆ័យទៅលើភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃពាក្យសុំ និងនីតិវិធីបន្ទាប់គឺជាការអនុវត្តដោយបង្ខំនូវខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលបានចេញ ដោយយកដីកាសម្រេចនេះធ្វើជាលិខិតអនុវត្ត[1] ។

### ២.១.លក្ខណៈពិសេស

ចំពោះនីតិវិធីរក្សាការពារ គឺមានលក្ខណៈពិសេសជាងនីតិវិធីបណ្តឹងអង្គសេចក្តី ឬ នីតិវិធីអនុវត្តដោយបង្ខំ។ បើប្រៀបធៀបទៅនឹងបណ្តឹងអង្គសេចក្តីនោះ គឺបណ្តឹងអង្គសេចក្តីប្រើពេលវេលាយូរណាស់ បើគិត តាំងពីពេលដាក់ពាក្យបណ្តឹងរហូតដល់ពេលចេញសាលក្រម និងចូលជាស្ថាពរ។ ម្យ៉ាងក្នុងអំឡុង ពេលដំណើរការនីតិវិធីបណ្តឹង បើសិនជាកូនបំណុលផ្ទេរទ្រព្យសម្បត្តិរបស់គាត់ទៅអោយតតិយជនតាមទំនើងចិត្តនោះ ទោះជាម្ចាស់បំណុលបានឈ្នះក្តីក៏មិនអាចអនុវត្តដោយបង្ខំបានដែរ។ ដើម្បីបង្កាកុំអោយមានបញ្ហាទាំងនេះ គេបង្កើតអោយមានយន្តការសង្គ្រោះជាបណ្តោះអាសន្ន ទម្រាំសិទ្ធិត្រូវបានសម្រេចជាស្ថាពរដោយសាលក្រមឬសាលដីកាស្ថាពរ នោះគឺនីតិវិធីរក្សាការពារ ។ នីតិវិធីនេះមានចរិកលក្ខណៈជា វិធីបណ្តោះអាសន្ន បន្ទាប់បន្សំ បន្ទាន់ និងសំងាត់ ។

### ២.២. សមត្ថកិច្ចតុលាការ

- តុលាការនៃនីតិវិធីរក្សាការពារត្រូវបានកំណត់ថាជាតុលាការដែលមានសមត្ថកិច្ចផ្តាច់មុខ [2]។

- រឿងក្តីរក្សាការពារត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើបណ្តឹង អង្គសេចក្តី[3] ។ តុលាការនៃបណ្តឹងអង្គសេចក្តី គឺជាតុលាការនៃរឿងក្តីដែលពាក្យបណ្តឹងត្រូវបានដាក់ ឬនៅមុនពេលពាក្យបណ្តឹងត្រូវបានដាក់ តុលាការមានសមត្ថកិច្ចគឺជាតុលាការដែលមានសមត្ថកិច្ចលើរឿងក្តីនៃបណ្តឹងនាពេលអនាគត។ ក្នុងករណីដែលមានតុលាការច្រើនមានសមត្ថកិច្ច ភាគីអាចជ្រើសយកតុលាការមួយជាតុលាការដែលចេញដីការក្សាការពារ ។

---

[1] មាត្រា ៥៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[2] មាត្រា ៥៣៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[3] មាត្រា ៥៤០ នៃក្រមនីតិវិធីរដ្ឋប្បវេណី

- ក្នុងករណីដែលសំណុំរឿងត្រូវបានចាត់ការដល់សាលាឧទ្ធរណ៍ នោះតុលាការដែលមានសមត្ថ-កិច្ចលើអង្គសេចក្តី គឺជាតុលាការនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ [4]។

- សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលនឹងត្រូវរឹបអូសជាបណ្តោះអាសន្ន ឬវត្ថុដែលជាកម្មវត្ថុវិវាទស្ថិតនៅ[5] ។ បើវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាចលនវត្ថុ ត្រូវបញ្ជាក់ពីទីកន្លែងនៃចលនវត្ថុនោះ ឬបើវត្ថុក្រៅពីចលនវត្ថុត្រូវបញ្ជាក់អំពីវត្ថុដែលជាកម្មវត្ថុនោះ ។ ក្នុងករណីដែលកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្នជា សិទ្ធិលើបំណុល ឬសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ត្រូវចាត់ទុកថា សិទ្ធិនោះស្ថិតនៅឯលំនៅឋានរបស់កូនបំណុលទី៣ ឬបុគ្គលដែលមានលក្ខណៈសម្បត្តិជាកូនបំណុលទី៣ [6] ។

## ៣. ប្រភេទនៃនីតិវិធីសម្រេចរក្សាការពារ

ដីកាសម្រេចរក្សាការពារត្រូវបានបែងចែកជាពីរធំៗ




---

[4] មាត្រា ៥៤០ កថាខណ្ឌ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[5] មាត្រា ៥៤០ កថាខណ្ឌ១នៃក្រមនីតិរដ្ឋប្បវេណី

[6] មាត្រា ៥៤០ កថាខណ្ឌទី៣ និងទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី

## ៣.១. ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នជាដីកាសម្រេចដែលមានគោលបំណងអោយសងជាប្រាក់។

ដីកាសម្រេចរឹបអូស ជាបណ្តោះអាសន្នត្រូវចេញនៅពេលដែលលក្ខខណ្ឌទាមទារសម្រាប់ការរឹបអូសជាបណ្តោះអាសន្ន ក៏ដូចជាលក្ខខណ្ឌចាំបាច់ផ្សេងទៀតសម្រាប់ការធ្វើបណ្តឹងត្រូវបានបំពេញសព្វគ្រប់។ ជាគោលការណ៍តុលាការត្រូវចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដោយកំណត់កម្មវត្ថុជាក់លាក់ លើកលែងតែដីកាសម្រេចរឹបអូសចលនវត្ថុជាបណ្តោះអាសន្ន ប៉ុណ្ណោះមិនបាច់កំណត់កម្មវត្ថុជាក់លាក់ទេ [7] ។

ដីកាសម្រេចប្រភេទនេះ តុលាការអាចធ្វើការសម្រេចដោយបង្គាប់អោយដាក់ប្រាតិភោគ ក៏បាន ឬមិនដាក់ក៏បាន តាមឆន្ទានុសិទ្ធិរបស់តុលាការ។ ការដាក់ប្រាតិភោគគឺជាមធ្យោបាយសម្រាប់ ធានាសំណងការខូចខាតដល់កូនបំណុល ក្នុងករណីដែលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នមានលក្ខណៈផ្ទុយពីការពិត ។

ចំពោះដីកាសម្រេចប្រភេទនេះ តុលាការត្រូវកំណត់ពីប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន (ប្រាក់រំដោះការរឹបអូសជាបណ្តោះអាសន្ន)[8] ដើម្បីអោយកូនបំណុលទទួលបានការលុបចោលនូវការអនុវត្តរឹបអូសជាបណ្តោះអាសន្ន [9]។ ការរឹបអូសជាបណ្តោះអាសន្ន មានគោលបំណងរក្សាការពារនូវការអនុវត្តដោយបង្ខំដែលមានគោលបំណងអោយសងជាប្រាក់ ហេតុនេះហើយការបើចំនួនទឹកប្រាក់ស្មើនឹងចំនួនទឹកប្រាក់នៃសិទ្ធិដែលត្រូវទាមទារដែលពាក់ព័ន្ធត្រូវបានផ្ញើ មានន័យថាប្រាក់ដែលត្រូវបានផ្ញើ នឹងត្រូវជំនួសអោយវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជា បណ្តោះអាសន្ន នោះម្ចាស់បំណុលនឹងមិនខូចខាត ហើយរក្សាការពារក៏អាចលុបបាន ។

### ៣.១.១. ខ្លឹមសារ

ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន គឺធ្វើការចាត់ចែងក្នុងកម្រិតនៃទ្រព្យសម្បត្តិរបស់កូនបំណុលដើម្បីរក្សាការពារការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងអោយសងជាប្រាក់[10] ។

អត្ថិភាពនៃសិទ្ធិលើបំណុលត្រូវតែកើតមាន (មានន័យថា ម្ចាស់បំណុលត្រូវតែបញ្ជាក់ដោយភស្តុតាងដែលអាចបង្ហាញថាខ្លួនពិតជាមានអត្ថិភាពសិទ្ធិលើបំណុលប្រាកដមែន )។

ការរឹបអូសជាបណ្តោះអាសន្ន គឺត្រូវរឹបអូសនូវទ្រព្យសម្បត្តិ(ជាក់លាក់) របស់កូនបំណុល ។ ទ្រព្យសម្បត្តិរបស់ កូនបំណុលអាច ជាចលនវត្ថុ អចលវត្ថុ ឬសិទ្ធិលើបំណុលជាដើម។

---

[7] មាត្រា ៥៤៦ ក្រមនីតិវិធីរដ្ឋប្បវេណី

[8] មាត្រា ៥៤២ ក្រមនីតិវិធីរដ្ឋប្បវេណី

[9] មាត្រា ៥៤៧ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី

[10] មាត្រា ៥៣១ ចំណុច ក ក្រមនីតិវិធីរដ្ឋប្បវេណី

### ៣.១.២ ភាពចាំបាច់[11]

ការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន មិនត្រឹមតែផ្អែកទៅលើអត្ថិភាពនៃសិទ្ធិដែលត្រូវបានរក្សាការពារប៉ុណ្ណោះទេ គឺត្រូវផ្អែកទៅលើភាពចាំបាច់នៃរក្សាការពារផងដែរ ។ ភាពចាំបាច់ដែលមានអត្ថិភាព គឺ ការអនុវត្តដោយបង្ខំនាពេលអនាគត និងមិនអាចធ្វើទៅបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ហេតុនេះត្រូវតែធ្វើអោយស្ថានភាពបច្ចុប្បន្នស្ថិតនៅដដែល ទើបអាចចាត់ទុកថា ការរក្សាការពារមានភាពចាំបាច់ ។

រក្សាការពារចាត់ទុកថាមានភាពចាំបាច់ ក្នុងករណីដែលស្ថានភាពទ្រព្យសម្បត្តិរបស់កូនបំណុលទំនងជានឹងធ្លាក់តម្លៃ ជាបរិមាណ ឬជាគុណភាព ឬនឹងមានតែទ្រព្យសម្បត្តិដែលពិបាកប្ដូរជាប្រាក់ នៅក្នុងការអនុវត្តដោយបង្ខំប៉ុណ្ណោះដែលនៅសល់ ដោយសារការចាយវាយខ្ជះខ្ជាយ ការលក់ក្នុងតម្លៃថោក ការខូចខាត ការបំបាត់ ជាអាទិ៍ ។ រក្សាការពារ ក៏ចាត់ទុកថាមានភាពចាំបាច់ដែរ ក្នុងករណីដែលកូនបំណុលបានគេចខ្លួន ឬបានប្ដូរលំនៅឋានច្រើនលើកច្រើនសារ ហើយបើការណ៍នោះ ត្រូវបានយល់ ឃើញថាជាឧបសគ្គចំពោះការអនុវត្តដោយបង្ខំ ។ អសាធនភាពរបស់កូនបំណុលនាពេលបច្ចុប្បន្ន មិនអាចធ្វើអោយរក្សាការពារមានភាពចាំបាច់នោះទេ ។ ដោយឡែកប្រសិនបើសាធនភាពរបស់កូនបំណុល មានភាពគ្រប់គ្រាន់ ហើយទំនងជានឹងអាចសម្រេចសិទ្ធិទាមទារបានដោយងាយស្រួលនោះ ភាពចាំបាច់នៃរក្សាការពារក៏នឹងត្រូវបដិសេធផងដែរ ។ ការបដិសេធរបស់កូនបំណុលចំពោះសិទ្ធិដែលត្រូវបានរក្សាការពារ ឬឥរិយាបទរបស់កូនបំណុលក្នុងការមិនព្រមអនុវត្តកាតព្វកិច្ចចំពោះសិទ្ធិនោះ ពុំមែនជាមូលហេតុនៃការបញ្ជាក់អំពីភាពចាំបាច់នៃការរក្សាការពារទេ ព្រោះសកម្មភាពទាំងនោះមិនមែនជាឧបសគ្គ ចំពោះការអនុវត្តដោយបង្ខំឡើយ ។ ត្រង់ចំណុចនេះ ចរិកលក្ខណៈរបស់ភាពចាំបាច់ក្នុងការរក្សាការពារ គឺខុសគ្នាពី "ភាពចាំបាច់ដែលតម្រូវអោយធ្វើការទាមទារជាមុន" ដែលជាលក្ខខណ្ឌសម្រាប់ធ្វើបណ្ដឹងទាមទារអោយផ្ដល់តាវកាលិកនាពេលអនាគត ។

ទោះបីជាបានបំពេញតាមលក្ខខណ្ឌទូទៅហើយក៏ដោយ ក៏ភាពចាំបាច់នៃការរក្សាការពារ អាចនឹងត្រូវបានបដិសេធដែរ ដូចជាករណីដែលសិទ្ធិលើបំណុលមានភ្ជាប់នឹងសិទ្ធិប្រាតិភោគប្រត្យក្សគ្រប់គ្រាន់ហើយ ឬករណីសិទ្ធិលើបំណុល បំពេញលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីធ្វើការអនុវត្តដោយបង្ខំដោយគ្មានលក្ខខណ្ឌ ។

ការបារម្ភថា ការអនុវត្តដោយបង្ខំទំនងជានឹងត្រូវធ្វើនៅបរទេស នោះការរក្សាការពារ ត្រូវចាត់ទុកថាមានភាពចាំបាច់ ។ ដូចជាកូនបំណុលបានបង្ហាញសញ្ញានៃការចាត់ចែងទ្រព្យសម្បត្តិ និងការធ្វើអន្តោប្រវេសន៍ទៅបរទេស ជាអាទិ៍ ។

---

[11] សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ទីព័រ ១៩៦

### ៣.១.៣ នីតិវិធីនៃការចេញដីកាសម្រេច

ចំពោះដីកាសម្រេចប្រភេទនេះ ការទាញហេតុផលដោយផ្ទាល់មាត់ គឺជាឆន្ទានុសិទ្ធិរបស់តុលាការ[12]ជាគោលការណ៍ត្រូវធ្វើឡើងជាសម្ងាត់ ប៉ុន្តែជាទូទៅដើម្បីអាចចេញដីកាសម្រេចបាន ដោយគ្រាន់តែសួរម្ចាស់បំណុលប៉ុណ្ណោះ។

ការសាកសួរភាគី គឺជាឆន្ទានុសិទ្ធិរបស់តុលាការ ហើយការសាកសួរនេះជានីតិវិធីមួយដែលផ្តល់ឪកាសអោយភាគីធ្វើសេក្តីថ្លែងការណ៍ចំពោះករណីនីមួយៗ ជាលាយលក្ខអក្សរ ឬដោយផ្ទាល់មាត់ តែមិនមានកំណត់អំពីទម្រង់ច្បាស់លាស់នោះទេ ។

## ៣.២. ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន

ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ត្រូវបានចែកចេញជាពីរ គឺដីកាសម្រេចចាត់ចែងជា បណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទ និងការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជា បណ្តោះអាសន្ន ហើយដីកាទាំងពីរប្រភេទនេះ គឺជាសិទ្ធិទាមទារដែលគ្មានគោលបំណងអោយសងជាប្រាក់។

### ៣.២.១. ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទ

**- ខ្លឹមសារ**

ដីកាសម្រេចនេះមានគោលបំណង ដើម្បីរក្សាស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនោះ ហេតុនេះសិទ្ធិទាមទារដែរត្រូវបានរក្សាការពារដោយការចាត់ចែងជាបណ្តោះអាសន្ន ដោយមានខ្លឹមសារជាការផ្លាស់ប្តូរ ឬមិនផ្លាស់ប្តូរនូវស្ថានភាពជាក់ស្តែង ឬទំនាក់ទំនងសិទ្ធិដែលមានលើវត្ថុ។ ពោលដីកាសម្រេចប្រភេទនេះ ជាការកម្រិតនូវសិទ្ធិចាត់ចែងវត្ថុដែលជាកម្មវត្ថុនៃវិវាទ[13] ។

ការចាត់ចែងជាបណ្តោះអាសន្នដោយហាមឃាត់មិនអោយចាត់ចែង (កូនបំណុលមិនអាចផ្ទេរ ឬដាក់បញ្ចាំ ហ៊ីប៉ូតែក ជួល និងចាត់ចែងគ្រប់ប្រភេទចំពោះអចលវត្ថុនានា ដោយផ្អែកលើកម្មសិទ្ធិ ។

**- ភាពចាំបាច់**[14]

ភាពចាំបាច់នៃការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទ ត្រូវបានទទួលស្គាល់ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិបាន ឬ និងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្ម

---

[12] មាត្រា៥៣៩ មាត្រា ១១៤ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[13] មាត្រា ៥៣១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[14] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ទំព័រ ២១០

វត្ថុនៃវិវាទ[15] ។ ករណីនេះ រួមមាន ករណីដែលមានហានិភ័យនៃការខូចខាត ការកែបំបាត់ ការផ្ទេរ ឬការរារាំងសិទ្ធិ លើវត្ថុដែលជាកម្មវត្ថុនៃវិវាទ ដោយកូនបំណុល ឬអ្នកផ្សេង ករណីដែលបុគ្គលណាម្នាក់កំពុងបន្តដំណើរការនៃការសាងសង់ ក្នុងខណៈដែលមានការទាមទារឲ្យដកចេញនូវការសាងសង់នោះ ករណីដែលបុគ្គលម្នាក់នាំបុគ្គលម្នាក់ផ្សេងទៀតរួមទាំងឥវ៉ាន់របស់គេ មករស់នៅជាមួយ ក្នុងខណៈដែលមានការទាមទារឲ្យបណ្ដេញចេញពីផ្ទះនោះ ករណីដែលបុគ្គលម្នាក់ចាប់ផ្ដើមការសាបព្រួសក្នុងខណៈដែលមានការទាមទារឲ្យប្រគល់ដីកសិកម្មនោះ ជាអាទិ៍។

**- នីតិវិធីនៃការចេញដីកាសម្រេច**

នីតិវិធីនៃការចេញដីកាសម្រេចប្រភេទនេះត្រូវអនុវត្តដូចគ្នា និងដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នផងដែល ថ្វីត្បិតតែគោលបំណងនៃដីកាទាំងពីរនេះមានភាពខុសគ្នា ប៉ុន្តែប្រើគោលការណ៍នៃដីការក្សាការពារដូចគ្នា គឺ ធ្វើជាសម្ងាត់ បន្ទាន់ និងឆាប់រហ័ស ។

### ៣.២.២. ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន

**- ខ្លឹមសារ**

ការចាត់ចែងដែលកំណត់ស្ថានភាពជាបណ្ដោះអាសន្នរហូតដល់សាលក្រម ឬ សាលដីកាចូលជាស្ថាពរ ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុលចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ[16]។

សិទ្ធិដែលត្រូវរក្សាការពារអាចជាសិទ្ធិលើទ្រព្យសម្បត្តិ ឬសិទ្ធិដែលទាក់ទងនឹងឋានៈបុគ្គល មានដូចជា ៖ កម្មសិទ្ធិ សិទ្ធិកាន់កាប់ សេរភាព សិទ្ធិលើនាម ទំនាក់ទំនងគតិយុត្តដែលបន្តដូចជា ភតិសន្យា កិច្ច-សន្យាការងារ ។ល។

ការរក្សាការពារឋានៈជាបុគ្គលិក(ការចាត់ចែងជាបណ្ដោះអាសន្ននៃការបង់ប្រាក់ឈ្នួលជាបណ្ដោះអាសន្ន)

ការកំណត់ជាបណ្ដោះអាសន្នអំពីឋានៈ ដែលមានសិទ្ធិក្នុងកិច្ចសន្យាការងាររបស់ម្ចាស់បំណុលចំពោះកូនបំណុល ។

ការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការអនុវត្តហ៊ីប៉ូតែក ជាអាទិ៍។

---

[15] មាត្រា ៥៩៨ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី

[16] មាត្រា ៥៣១ ចំណុចគ ក្រមនីតិវិធីរដ្ឋប្បវេណី

**- ភាពចាំបាច់**[17]

ភាពចាំបាច់នៃការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន ត្រូវបានទទួលស្គាល់ ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ[18]។

**- នីតិវិធីនៃការចេញដីកាសម្រេច**

តុលាការ មិនអាចចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោ-អាសន្នបានឡើយ បើមិនឆ្លងកាត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ តាមកាលបរិច្ឆេទនៃការសួរដែលកូនបំណុលអាចចូលរួមបាន[19]។ ទោះបីជាមូលដ្ឋាន ការចាត់ចែងជាបណ្ដោះអាសន្ន ត្រូវធ្វើជាសម្ងាត់ដូចករណីនៃការរឹបអូសជាបណ្ដោះអាសន្នក៏ដោយ នៅក្នុងការចាត់ចែងជាបណ្ដោះអាសន្ន ដែលកំណត់ឋានៈជាបណ្ដោះអាសន្ន ផលប្រយោជន៍របស់ម្ចាស់បំណុលនៅតែត្រូវបានការពារទោះជាគ្មានការវិនិច្ឆ័យជាសម្ងាត់ក៏ដោយ ហើយម្យ៉ាងទៀត បើនីតិវិធីនេះធ្វើឡើងដោយសម្ងាត់នោះនឹងនាំឲ្យមានការប៉ះពាល់ធ្ងន់ធ្ងរដល់កូនបំណុល ។ ហេតុនេះហើយបានជាច្បាប់ផ្ដល់ឪកាសឲ្យដល់កូនបំណុលក្នុងការការពារខ្លួន នៅក្នុងការចាត់ចែងជាបណ្ដោះអាសន្នប្រភេទនេះ ។ ក៏ប៉ុន្តែបើមានស្ថានភាពពិសេសដែលនាំអោយពុំអាចសម្រេចគោលបំណងនៃពាក្យសុំអោយចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដោយសារឆ្លងតាមកាលបរិច្ឆេទនៃការទាញហេតុផលផ្ទាល់មាត់ជាអាទិ៍ នោះដីកាសម្រេចចាត់ចែង ជាបណ្ដោះអាសន្នអាចចេញបាន ដោយមិនចាំបាច់ឆ្លងតាមកាលបរិច្ឆេទនៃការទាញហេតុផលផ្ទាល់មាត់ទេ [20]។

=========

---

[17] សេចក្ដីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ទំព័រ ២១១

[18] មាត្រា ៥៩៨ ក្រមនីតិវិធីរដ្ឋប្បវេណី

[19] មាត្រា ៥៩៨ កថាខណ្ឌទី៤ វាក្យខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី

[20] មាត្រា ៥៩៨ កថាខណ្ឌទី៤ វាក្យខណ្ឌទី២